ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ០៥៨២ ព.ណ.នផ....

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០២១

# សេចក្ដីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី អ្នកនាង កញ្ញា ដែលជាផលិតករ ឬអ្នកនាំចេញទាំងអស់ឱ្យបានជ្រាបថា ចាប់តាំងពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ ប្រព័ន្ធស្វ័យប្រវត្តកម្មវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញរបស់ក្រសួងពាណិជ្ជកម្ម មិនអាចដំណើរការជាប្រក្រតីបានឡើយ ដោយសារជួបបញ្ហាបច្ចេកទេស "Cloud Dedicated Servers"។

ក្រសួងពាណិជ្ជកម្ម បានរៀបចំប្រព័ន្ធស្វ័យប្រវត្តកម្មបណ្ដោះអាសន្ន (Interim Solution) ក្នុងការផ្ដល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញគ្រប់ទម្រង់ ជូនក្រុមហ៊ុននាំចេញ តាមរយៈគេហទំព័រ coo.moc.gov.kh រហូតដល់ប្រព័ន្ធស្វ័យប្រវត្តកម្មវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញអាចដំណើរការប្រក្រតីឡើងវិញ។

អាស្រ័យហេតុនេះ សូម អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី អ្នកនាង កញ្ញា ដែលជាផលិតករ ឬ អ្នកនាំចេញទាំងអស់ មេត្តាជ្រាប និងចូលរួមអនុវត្តនូវប្រព័ន្ធស្វ័យប្រវត្តកម្មបណ្ដោះអាសន្ន (Interim Solution) ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

សូមអរគុណ!

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469